ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"

Cambodian Reinsurance Company "Cambodia Re"

ដៃគូដើម្បីស្ថិរភាព និងភាពជោគជ័យ

Partner for Stability and Success

របាយការណ៍ ប្រចាំឆ្នាំ

២០២៤

www.cambodiare.com.kh

មាតិកា

1. សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល 01

2. សេចក្តីថ្លែងរបស់អគ្គនាយក 02

3. ទីផ្សារធានារ៉ាប់រងកម្ពុជា: ភាពរីកចម្រើន និងបញ្ហារប្រឈម 05

- ធានារ៉ាប់រងទូទៅ 05
- ធានារ៉ាប់រងអាយុជីវិត 09
- ធានារ៉ាប់រងខ្នាតតូច 11

4. អំពីក្រុមហ៊ុន កម្ពុជា រី 12

- សវតាក្រុមហ៊ុន 12
- ភាគហ៊ុននិក 12
- ព្រឹត្តិការណ៍សំខាន់ៗ 13
- ចក្ខុវិស័យ និង បេសកកម្ម, គុណតម្លៃ 14-15
- ការគ្រប់គ្រងសាជីវកម្ម និងភាពជាអ្នកដឹកនាំ 15
- ក្រុមប្រឹក្សាភិបាល 16
- គណៈគ្រប់គ្រងសំខាន់ៗ 19

5. លទ្ធផលហិរញ្ញវត្ថុ 22

- បុព្វលាភធានារ៉ាប់រងដុល 22
- សំណងទូទាត់ដុល 23

- ចំណេញពីធានារ៉ាប់រង និងប្រាក់ចំណេញសុទ្ធ 24

6. ការគ្រប់គ្រងហានិភ័យ 24

7. សមិទ្ធផលសំខាន់ៗ 24

8. ភាពជាដៃគូ 25

9. ការគ្រប់គ្រងការវិនិយោគ 26

10. ការលើកកម្ពស់ជំនាញធានារ៉ាប់រងតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ 27

- ការចូលរួមវិស័យ និងព្រឹត្តិការណ៍ឯកទេស 29

- សកម្មភាពទទួលខុសត្រូវខាងសង្គម 31

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល



ខ្ញុំពិតជាមានមោទនភាព និងសុទិដ្ឋិនិយមយ៉ាងខ្លាំង ដើម្បីបង្ហាញជូនអំពីភាពរីកចម្រើនដ៏គួរឱ្យកត់សម្គាល់របស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា “កម្ពុជា រី”។ ខ្ញុំមានឱកាសពិសេសដែលបានពិនិត្យឃើញដោយផ្ទាល់ភ្នែកនូវការវិវត្តនៃវិស័យដ៏សំខាន់នេះនៅក្នុងសេដ្ឋកិច្ចរបស់យើង។

ខណៈដែលកម្ពុជាបន្តស្ថិតនៅលើផ្លូវនៃកំណើនសេដ្ឋកិច្ច និងបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច វិស័យធានារ៉ាប់រងឈរជាសសរស្តម្ភដ៏សំខាន់ក្នុងការលើកកម្ពស់សុវត្ថិភាពហិរញ្ញវត្ថុ ទំនុកចិត្តវិនិយោគ និងភាពធន់នៃសេដ្ឋកិច្ចក្នុងរយៈពេលវែង។ ភាពរីកចម្រើននៃនគរូបនីយកម្ម ការរីកលូតលាស់នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការកើនឡើងនៃសកម្មភាពធុរកិច្ច ធ្វើឱ្យមានការកើនឡើងនូវតម្រូវការជាប្រចាំនៃដំណោះស្រាយកាត់បន្ថយហានិភ័យ។

ការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះពពិធកម្មសេដ្ឋកិច្ច, ភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុ និងការពង្រឹងបទប្បញ្ញត្តិ បានផ្តល់បរិយាកាសគាំទ្រសម្រាប់ភាពរីកចម្រើននៃទីផ្សារធានារ៉ាប់រង។ គំនិតផ្តួចផ្តើមគោលនយោបាយនានាដែលមានបំណងបង្កើនបរិយាប័ន្នហិរញ្ញវត្ថុ កែលម្អក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ និងលើកកម្ពស់ការយល់ដឹងអំពីធានារ៉ាប់រង គឺជាកត្តារួមចំណែកដល់ការបង្កើនអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច។

ក្រុមហ៊ុន កម្ពុជា រី បានដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងប្រព័ន្ធអេកូឡូស៊ីធានារ៉ាប់រង រួមចំណែកដល់ស្ថិរភាពទីផ្សារ និងគាំទ្រដល់ក្រុមហ៊ុនធានារ៉ាប់រងនានាក្នុងការផ្តល់នូវការធានារ៉ាប់រងលើហានិភ័យសម្រាប់ធុរកិច្ច និងបុគ្គលនានា។

ដោយពិនិត្យឃើញនូវកង្វះខាតជំនាញវិជ្ជាជីវៈដើម្បីទ្រទ្រង់កំណើនវិស័យធានារ៉ាប់រងប្រកបដោយចីរភាព ក្រុមហ៊ុន កម្ពុជា រី បន្តប្តេជ្ញាក្នុងការអភិវឌ្ឍជំនាញ និងសមត្ថភាពវិជ្ជាជីវៈធានារ៉ាប់រង។ តាមរយៈការអនុវត្តគំនិតផ្តួចផ្តើមនូវកម្មវិធីបណ្តុះបណ្តាល និងចែករំលែកចំណេះដឹងនានា ក្រុមហ៊ុនបានគាំទ្រដល់ភាពរីកចម្រើននៃជំនាញបច្ចេកទេសក្នុងការគ្រប់គ្រងហានិភ័យ និងធានារ៉ាប់រង។ ការវិនិយោគលើមូលធនមនុស្ស មានសារៈសំខាន់ក្នុងការធានាបាននូវទីផ្សារធានារ៉ាប់រងដ៏រឹងមាំ និងមានភាពធន់ ដែលអាចបម្រើតម្រូវការសេដ្ឋកិច្ចកម្ពុជាដែលមានការវិវត្តន៍ជាប្រចាំបានយ៉ាងមានប្រសិទ្ធភាព។

ក្រុមហ៊ុន កម្ពុជា រី នឹងបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគាំទ្រការពង្រឹងវិស័យធានារ៉ាប់រង ដោយផ្តល់នូវសេវាធានារ៉ាប់រងបន្តដែលអាចជឿទុកចិត្តបាន លើកកម្ពស់ស្ថិរភាពទីផ្សារ និងជំនាញវិជ្ជាជីវៈ។ ជារួម ក្រុមហ៊ុន កម្ពុជា រី រំពឹងថាការប្តេជ្ញារបស់ខ្លួនក្នុងការពង្រឹងវិស័យធានារ៉ាប់រងនឹងរួមចំណែកដល់គោលដៅរយៈពេលវែងរបស់ប្រទេសកម្ពុជាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងភាពរុងរឿង។

យើងសូមអរគុណចំពោះទំនុកចិត្ត និងការសហការរបស់ដៃគូអាជីវកម្ម និងភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យធានារ៉ាប់រង ដែលខិតខំប្រឹងប្រែងរួមគ្នាជំរុញវិស័យធានារ៉ាប់រងប្រកបដោយភាពធន់ និងបរិយាបន្នទៅអនាគត។ ក្រុមហ៊ុន កម្ពុជា រី បន្តចូលរួមយ៉ាងសកម្មក្នុងការសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា និងនិយ័តករធានារ៉ាប់រងកម្ពុជាដើម្បីលើកកម្ពស់ចំណេះដឹងអំពីការធានារ៉ាប់រង និងអប់រំសាធារណជនអំពីសារៈសំខាន់នៃការរៀបចំផែនការហិរញ្ញវត្ថុរយៈពេលវែង។

ជាកិច្ចបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគីពាក់ព័ន្ធទាំងអស់សម្រាប់ការជឿទុកចិត្ត ការសហការ និងការប្តេជ្ញារួមគ្នា។ យើងទាំងអស់គ្នារួមគ្នាអភិវឌ្ឍទីផ្សារធានារ៉ាប់រងមួយដែលជាមូលដ្ឋានសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាពនៅកម្ពុជា។

ដោយក្តីគោរព

រស់ សីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

សេចក្តីថ្លែងរបស់អគ្គនាយក



ក្នុងឆ្នាំ 2024កន្លងមក ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយបានពង្រឹងខ្លួនឱ្យក្លាយជាកត្តាជំរុញមួយក្នុងចំណោមកត្តាជំរុញគន្លឹះជាច្រើនក្នុងវិស័យធានារ៉ាប់រងនៅកម្ពុជា។ ក្រុមហ៊ុន កម្ពុជា រី បន្តប្តេជ្ញាចិត្តក្នុងការរួមចំណែកដល់ការពង្រឹងវិស័យធានារ៉ាប់រងនៅកម្ពុជាប្រកបដោយភាពធន់ និងជវភាព។

ជាមួយនឹងវត្តមានយូរអង្វែងនៅក្នុងទីផ្សារ ក្រុមហ៊ុន កម្ពុជា រី ប្តេជ្ញាលើកកម្ពស់ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងឱ្យមានការប្រកួតប្រជែងដោយភាពត្រឹមត្រូវ។ យើងព្យាយាមគ្រប់លទ្ធភាពដើម្បីធានាថាក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ទោះធំក្តី តូចក្តី អាចមានឱកាសដូចគ្នាក្នុងការទទួលបានសេវាធានារ៉ាប់រងបន្តដែលអាចទុកចិត្តបានរបស់ក្រុមហ៊ុន កម្ពុជា រី តាមរយៈការកំណត់ថ្លៃសេវារបស់ខ្លួនប្រកបដោយភាពប្រកួតប្រជែង និងសង្គតិភាព ក្រុមហ៊ុន កម្ពុជា រី ជួយបង្កើតឱ្យឱ្យមានស្ថានភាពដែលអនុញ្ញាតឱ្យឱ្យក្រុមហ៊ុនធានារ៉ាប់រងអាចប្រកួតប្រជែងដោយភាពត្រឹមត្រូវនិងចីរភាព។ អភិក្រមរបស់យើងមិនត្រឹមតែពង្រឹងស្ថិរភាពទីផ្សារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញកំណើនរយៈពេលវែង និងភាពធន់នៅក្នុងវិស័យផងដែរ។

ក្រុមហ៊ុន កម្ពុជា រី បន្តរីកចម្រើនដោយសម្រេចបានកំណើនហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់ ជាមួយនឹងបុព្វលាភដុលសរុបកើនឡើងជិត 40% ពោលគឺកើនឡើងពី 14.3 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2020 ដល់ 19,9 លានដុល្លារអាម៉េរិក ក្នុងឆ្នាំ 2024 ដែលឆ្លុះបញ្ចាំងពីភាពធន់ និងយុទ្ធសាស្ត្ររបស់ខ្លួននៅក្នុងទីផ្សារធានារ៉ាប់រងដែលចេះតែមានការរីកធំធាត់ឡើង។ និន្នាការកើនឡើងនេះគឺស្របនឹងកំណើនជារួមនៃទីផ្សារធានារ៉ាប់រង ដែលបុព្វលាភសរុបមានចំនួន 357លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2024 កើនឡើង 37% ក្នុងរយៈពេលដូចគ្នា។ ការរីកចម្រើនព្រមគ្នានេះ បង្ហាញពីសមត្ថភាពរបស់ក្រុមហ៊ុន កម្ពុជា រី ក្នុងការចាប់យកកាលានុវត្តភាពទីផ្សារ ការពង្រឹងលទ្ធភាពទទួលយកហានិភ័យធានារ៉ាប់រងបន្ត និងការគាំទ្រដល់ការរីកលូតលាស់កាន់តែទូលំទូលាយរបស់វិស័យធានារ៉ាប់រង។

ក្នុងដំណើរឆ្ពោះទៅអនាគត ក្រុមហ៊ុន កម្ពុជា រី ត្រៀមខ្លួនរួចជាស្រេចសម្រាប់ការបន្តចាប់យកកំណើនធុរកិច្ច និងការដើរតួកាន់តែធំទូលាយនៅក្នុងការអភិវឌ្ឍវិស័យធានារ៉ាប់រង តាមរយៈការប្រើប្រាស់ជំនាញ និងការយល់ដឹងអំពីទីផ្សារ។ ជាមួយនឹងការបន្តកើនឡើងនៃសេដ្ឋកិច្ច ក៍ដូចជាការកើនឡើងនៃអត្រាភាគទានធានារ៉ាប់រងនៅក្នុងសេដ្ឋកិច្ចនៅកម្ពុជា ក្រុមហ៊ុន កម្ពុជា រី មានសក្តានុពលយ៉ាងខ្លាំងក្នុងការពង្រឹងវត្តមានរបស់ខ្លួនបន្ថែមទៀតនៅក្នុងទីផ្សារធានារ៉ាប់រង និងរួមចំណែកដល់ការរីកចម្រើន និងស្ថេរភាពនៃប្រព័ន្ធអេកូឡូស៊ីធានារ៉ាប់រងនៅកម្ពុជា។


ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសហការីដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការផ្តល់សេវាជូនអតិថិជន និងដៃគូធុរកិច្ចនិងភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកដល់ភាពជោគជ័យរបស់ ក្រុមហ៊ុន កម្ពុជា រី នៅឆ្នាំ 2024។ យើងប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការរួមចំណែកដល់ការពង្រឹងវិស័យធានារ៉ាប់រងកម្ពុជា និងការកសាងសុវត្ថិភាពផ្នែកហិរញ្ញវត្ថុសម្រាប់អនាគតទាំងអស់គ្នា។

ដោយក្តីគោរព

ហ៊ុយ វ៉ាថារ៉ូ

អគ្គនាយក

ទីផ្សារធានារ៉ាប់រងកម្ពុជា
ភាពរីកចម្រើន និងបញ្ហាប្រឈម



ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

បុព្វលាភដុលទីផ្សារ ឆ្នាំ 2024 **$357 លាន**


អាយុជីវិត **$200 លាន**

ទូទៅ **$148 លាន**


ខ្នាតតូច **$9 លាន**

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ វិស័យធានារ៉ាប់រងកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែលបុព្វលាភសរុបកើនឡើង 37% គឺកើនឡើងពី 260.6លានដុល្លារអាម៉េរិកក្នុងឆ្នាំ2020 ដល់ 357 លានដុល្លារអាម៉េរិកក្នុងឆ្នាំ2024 បើទោះបីជាសេដ្ឋកិច្ចពិភពលោកមានភាពមិនប្រាកដប្រជាក៏ដោយ។ ការកើនឡើងនេះត្រូវបានរុញច្រានដោយការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ការកើនឡើងនៃការយល់ដឹងជាសាធារណៈអំពីធានារ៉ាប់រង ការកែលម្អបទប្បញ្ញត្តិ និងការកើនឡើងនៃការវិនិយោគបរទេស។ ធានារ៉ាប់រងអាយុជីវិតនៅតែជាផ្នែកលេចធ្លោ ដោយរួមចំណែក 56% (200 លានដុល្លារអាម៉េរិក) នៃបុព្វលាភសរុប ខណៈពេលដែលធានារ៉ាប់រងទូទៅមានចំនួន 41.5% (148 លានដុល្លារអាម៉េរិក) និងធានារ៉ាប់រងខ្នាតតូច 2.5% (9 លានដុល្លារអាម៉េរិក) ដែលឆ្លុះបញ្ចាំងពីភាពសម្បូរបែបនៃផលិតផលធានារ៉ាប់រង និងការផ្តល់សេវាដល់ដៃអ្នកប្រើប្រាស់។

បុព្វលាភដុលទីផ្សារតាមប្រភេទផលិតផល (%)



ធានារ៉ាប់រងទូទៅ



ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា


បុព្វលាភដុលទីផ្សារធានារ៉ាប់រងទូទៅ តាមផលិតផល ឆ្នាំ 2024

ទ្រព្យសម្បត្តិ	**$51.5 លាន**	យានយន្ត	**$24.1 លាន**	គ្រោះថ្នាក់បុគ្គល	**$7.9 លាន**	ផ្សេងៗ	**$14.5 លាន**
សុខភាព	**$33.4 លាន**	វិស្វកម្ម	**$9.2 លាន**	នាវា និងដឹកជញ្ជូន	**$7.4 លាន**	**សរុប**	**$148 លាន**

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ វិស័យធានារ៉ាប់រងទូទៅរបស់កម្ពុជាមានកំណើនគួរឱ្យកត់សម្គាល់ ដោយបុព្វលាភធានារ៉ាប់រងបានកើនឡើង 30% គឺកើនពី 113.8 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2020 ដល់ 148 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2024។ ទោះជាយ៉ាងណាក៏ដោយ អត្រាកំណើនប្រចាំឆ្នាំមានការថមថយពី 8.3% ក្នុងឆ្នាំ 2023 មក 5.3% ក្នុងឆ្នាំ 2024។

កត្តាចម្បងនៃកំណើននេះរួមចំណែកមកពី ការធានារ៉ាប់រងទ្រព្យសម្បត្តិ យានយន្ត និងសុខភាព។ ការធានារ៉ាប់រងទ្រព្យសម្បត្តិនៅតែមានចំណែកទីផ្សារធំជាងគេក្នុងឆ្នាំ2024 ដែលមានចំនួន 35% នៃបុព្វលាភសរុបគិតជាទឹកប្រាក់ចំនួន 51.5 លានដុល្លារអាម៉េរិក កើនឡើង 5.3% ធៀបនឹងឆ្នាំ2023។ ការធានារ៉ាប់រងសុខភាពមានចំណែកទីផ្សារ 23% ដែលគិតជាទឹកប្រាក់ចំនួន 33.4 លានដុល្លារអាម៉េរិក កើនឡើង 6% ខណៈដែលការធានារ៉ាប់រងយានយន្តមានចំណែកទីផ្សារ 16% ដែលគិតជាទឹកប្រាក់ចំនួន 24.1 លានដុល្លារអាម៉េរិកកើនឡើងត្រឹម 0.4%។


ការធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល និងការធានារ៉ាប់រងគ្រោះថ្នាក់ផ្សេងៗក៏បានបង្ហាញពីការកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ2024 ជាមួយនឹងអត្រាកំណើន 11.8% គឺកើនដល់ 7.9 លានដុល្លារអាម៉េរិក និងអត្រាកំណើន 5.7% គឺកើនដល់ 14.5 លានដុល្លារអាម៉េរិក រៀងគ្នា។ ផ្ទុយទៅវិញ ការធានារ៉ាប់រងផ្នែកនាវា និងដឹកជញ្ជូនបានធ្លាក់ចុះ 12.4% គឺធ្លាក់ដល់ 7.4 លានដុល្លារអាម៉េរិក ហើយការធានារ៉ាប់រងវិស្វកម្មបានធ្លាក់ចុះ 3% គឺធ្លាក់ដល់ 9.2 លានដុល្លារអាម៉េរិក។



ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

បុព្វលាភដុល និងសំណងដុល (មិនរួមបញ្ចូល IBNR) ទីផ្សារធានារ៉ាប់រងទូទៅ ឆ្នាំ2024

បុព្វលាភដុល	សំណងដុល(មិនរួមបញ្ចូល IBNR)
$148 លាន	**$52.5 លាន**



ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

សំណងដុល (មិនរួមបញ្ចូល IBNR) ទីផ្សារធានារ៉ាប់រងទូទៅ តាមផលិតផល ឆ្នាំ 2024

សុខភាព	**$22.8 លាន**	នាវា និងការដឹកជញ្ជូន	**$0.4 លាន**
ទ្រព្យសម្បត្តិ	**$15.8 លាន**	វិស្វកម្ម	**$0.3 លាន**
យានយន្ត	**$10.4 លាន**	ផ្សេងៗ	**$0.5 លាន**
គ្រោះថ្នាក់បុគ្គល	**$2 លាន**		


សរុប $52.5 លាន

សំណងលើធានារ៉ាប់រងយានយន្ត សុខភាព និងទ្រព្យសម្បត្តិមានការកើតឡើងកាន់តែញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ។ នៅឆ្នាំ 2024 សំណងធានារ៉ាប់រងសុខភាពមានចំនួនសរុបជាទឹកប្រាក់ 22.8 លានដុល្លារអាម៉េរិក។

ស្រដៀងគ្នានេះដែរ សំណងធានារ៉ាប់រងយានយន្តមានការកើនឡើងកាន់តែខ្ពស់។ ខណៈបុព្វលាភធានារ៉ាប់រងយានយន្តមានកំណើនត្រឹម 0.4% ការទូទាត់សំណងលើធានារ៉ាប់រងប្រភេទនេះបានកើនឡើងយ៉ាងខ្លាំងដល់ 12% ក្នុងឆ្នាំ 2024។

សំណងធានារ៉ាប់រងទ្រព្យសម្បត្តិក្នុងឆ្នាំ 2024 មានការកើនឡើងដល់ទៅ 85% ធៀបនឹងឆ្នាំ 2023 ដោយសារតែអគ្គីភ័យបានកើតឡើងចំពោះរោងចក្រធំៗចំនួនពីរគឺ រោងចក្រផលិតស្បែកជើង មានការខូចខាតគិតជាទឹកប្រាក់ 8.2 លានដុល្លារអាម៉េរិក និង រោងចក្រកាត់ដេរសំលៀកបំពាក់ មានការខូចខាតគិតជាទឹកប្រាក់ 4.5 លានដុល្លារអាម៉េរិក។ ឧប្បត្តិហេតុទាំងនេះបង្ហាញពីតម្រូវការនៃការវាយតម្លៃហានិភ័យដ៏ប្រសើរ និងដំណោះស្រាយការធានាទូលំទូលាយ។

ធានារ៉ាប់រងអាយុជីវិត



ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា


បុព្វលាភដុលទីផ្សារធានារ៉ាប់រងអាយុជីវិត តាមផលិតផល2024

ទាយជ្ជទាន	**$164 លាន**	ជាក្រុម	**$15.9 លាន**
កាលកំណត់	**$18.7 លាន**	ផ្សេងៗ	**$1.9 លាន**

សរុប $200.2 លាន

វិស័យធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលក្នុងនោះបុព្វលាភដុលមានកំណើន 31.5% គឺកើនពី 152.3 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2020 ដល់ 200.2 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2024 ។ ទោះជាយ៉ាងណាក៏ដោយ កំណើននេះបានថយចុះមកនៅប្រហែល 2.8% ក្នុងឆ្នាំ 2024 ។

ផលិតផលធានារ៉ាប់រងអាយុជីវិតមានកាលកំណត់បានកើនឡើង 10.3% ខណៈដែលការធានារ៉ាប់រងទាយជ្ជទានមានការកើនឡើងតិចតួចប្រមាណ 2.5% ដែលអាចបង្ហាញពីការផ្លាស់ប្តូរឥរិយាបទរបស់អ្នកប្រើប្រាស់។ ទោះយ៉ាងណាក៏ដោយ ផលិតផលធានារ៉ាប់រងទាយជ្ជទាននៅតែមានចំណែកលើសលប់នៅក្នុងផ្នែកធានារ៉ាប់រងអាយុជីវិត។




ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

សំណងបានទូទាត់ ទីផ្សារធានារ៉ាប់រងអាយុជីវិត 2024

អត្ថប្រយោជន៍ដល់កាលកំណត់	**$9.9 លាន**	ការបោះបង់បណ្ណសន្យារ៉ាប់រង	**$6 លាន**	**សរុប**	**$32.7 លាន**
មរណភាព	**$10.2 លាន**	ផ្សេងៗ	**$6.5 លាន**		

សំណងដុលដែលបានទូទាត់សរុបសម្រាប់វិស័យធានារ៉ាប់រងអាយុជីវិតបានកើនឡើង 104% ក្នុងឆ្នាំ2024 ពោលគឺកើនដល់ 32.7 លានដុល្លារអាម៉េរិកធៀបនឹងទឹកប្រាក់សំណងដុល 16លានដុល្លារអាម៉េរិកក្នុងឆ្នាំ2023។ ប្រហែល 2ភាគ3 នៃសំណងដុលសរុប ត្រូវបានទូទាត់សម្រាប់បណ្ណសន្យារ៉ាប់រងដល់កាលកំណត់ និងការផ្តល់អត្ថប្រយោជន៍ចំពោះអ្នកទទួលផលដែលបណ្តាលមកពីមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញពីសេចក្តីទុកចិត្ត និងភាពជឿជាក់របស់សាធារណៈជនមកលើវិស័យធានារ៉ាប់រង ហើយក៏ជាការឆ្លុះបញ្ចាំងពីការបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការផ្តល់នូវស្ថិរភាពហិរញ្ញវត្ថុជូនក្រុមគ្រួសារដែលត្រូវបានធានារ៉ាប់រង។

ធានារ៉ាប់រងខ្នាតតូច



ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

បុព្វលាភដុល ទីផ្សារធានារ៉ាប់រងខ្នាតតូច ឆ្នាំ 2024

អាយុជីវិត	**$7.46 លាន**	សុខភាព	**$0.58 លាន**	**សរុប $8.84 លាន**
យានយន្ត	**$0.74 លាន**	គ្រោះថ្នាក់បុគ្គល	**$0.05 លាន**	

ផ្នែកធានារ៉ាប់រងខ្នាតតូចបានកើនឡើង 23% ធៀបនឹងឆ្នាំកន្លងទៅ និងកើនឡើង64% ក្នុងរយៈពេលពីឆ្នាំ2020-2024 ដោយទទួលបានបុព្វលាភ 8.84 លានដុល្លារអាម៉េរិក ក្នុងឆ្នាំ 2024 ដែលកំណើននេះរុញច្រានដោយការកើនឡើងនៃផលិតផលធានារ៉ាប់រងអាយុជីវិតខ្នាតតូច។ សមាសភាពនៃទីផ្សារបានផ្លាស់ប្តូរយ៉ាងខ្លាំង ដោយផលិតផលធានារ៉ាប់រងអាយុជីវិតខ្នាតតូចដែលមានចំណែក 43% ក្នុងឆ្នាំ 2020 បានកើនដល់ 84% ក្នុងឆ្នាំ2024 ដែលមាន បុព្វលាភចំនួន 7.46 លានដុល្លារអាម៉េរិក។ ចំណែកនៃការធានារ៉ាប់រងសុខភាព យានយន្ត និងគ្រោះថ្នាក់បុគ្គលនៅក្នុងផ្នែកធានារ៉ាប់រងខ្នាតតូចមានចំនួនត្រឹមតែ 15.5% ប៉ុណ្ណោះ ដែលបង្ហាញពីការពឹងផ្អែកកាន់តែខ្លាំងរបស់វិស័យនេះលើការធានារ៉ាប់រងអាយុជីវិតខ្នាតតូចសម្រាប់សុវត្ថិភាពហិរញ្ញវត្ថុរយៈពេលវែង។

សំណងធានារ៉ាប់រងខ្នាតតូចបានកើនឡើង 43.3% នាំមុខដោយសំណងធានារ៉ាបរងអាយុជីវិតខ្នាតតូចដែលមានចំណែក 60.7% នៃសំណងធានារ៉ាប់រងខ្នាតតូចសរុប ដែលបង្ហាញពីការពង្រីកតួនាទីរបស់វិស័យនេះក្នុងការផ្តល់នូវការការពារហិរញ្ញវត្ថុជូនអតិថិជន។


អំពីក្រុមហ៊ុន កម្ពុជា រី

សវតាក្រុមហ៊ុន

ក្រុមហ៊ុន កម្ពុជា រី បន្តរីកចម្រើនស្របតាមការអភិវឌ្ឍទីផ្សារធានារ៉ាប់រង និងកំណើនសេដ្ឋកិច្ច។ ជាសហគ្រាសរដ្ឋដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2002 ក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ក្រុមហ៊ុន កម្ពុជា រី ត្រូវបានបង្កើតឡើងដើម្បីគាំទ្រទីផ្សារធានារ៉ាប់រងកម្ពុជាដែលទើបចាប់កំណើតឡើង។ ដោយទទួលស្គាល់ពីសក្តានុពលសម្រាប់ការរីកចម្រើន និងបទពិសោធន៍ជំនាញនៅក្នុងតំបន់ ក្រុមហ៊ុនក៏បានប្រែក្លាយខ្លួនទៅជាក្រុមហ៊ុនចម្រុះរដ្ឋក្នុងឆ្នាំ 2004 រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុន Asian Insurance International Holding (AII) ដែលជាសម្ព័ន្ធនៃក្រុមហ៊ុនធានារ៉ាប់រងមួយចំនួននៅក្នុងតំបន់។

នៅឆ្នាំ 2019 ក្រុមហ៊ុនកម្ពុជា រី បានពង្រឹងរចនាសម្ព័ន្ធភាគហ៊ុនិក ដោយបានចាប់ដៃគូបន្ថែមជាមួយភាគហ៊ុនិកយុទ្ធសាស្ត្រ 2 ទៀតគឺ ក្រុមហ៊ុន Forte Investment Holding Co., Ltd. និងក្រុមហ៊ុន Sovannaphum Life Assurance Plc ដែលជាការធ្វើឱ្យមានពិពិធកម្មភាគហ៊ុនិកកាន់តែទូលំទូលាយ ទាំងផ្នែកហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ។ ការវិវត្តន៍នេះបង្ហាញពីតួនាទីកាន់តែសំខាន់របស់ក្រុមហ៊ុននៅក្នុងវិស័យធានារ៉ាប់រងនៅកម្ពុជា និងសមត្ថភាពរបស់ខ្លួនក្នុងការសម្របខ្លួនទៅនឹងតម្រូវការដែលកំពុងកើនឡើងរបស់ទីផ្សារនេះ។

ភាគហ៊ុនិក



ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់ជាតិ ក្រុមហ៊ុន កម្ពុជា រី បានអភិវឌ្ឍការយល់ដឹងស៊ីជម្រៅអំពីប្រវត្តិហានិភ័យក្នុងស្រុក និងជរភាពនៃទីផ្សារ ដែលអនុញ្ញាតឱ្យយើងផ្តល់នូវដំណោះស្រាយផ្នែរហានិភ័យសមស្របជូនក្រុមហ៊ុនធានារ៉ាប់រងដៃគូ។ ក្រុមហ៊ុន កម្ពុជា រី ផ្តល់នូវសេវាកម្មធានារ៉ាប់រងបន្តដែលមានភាពទូលំទូលាយទាំងធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត ដែលធានាបាននូវស្ថិរភាព និងកំណើនសម្រាប់ទីផ្សារនេះ។ ក្រៅពីការធានារ៉ាប់រងបន្តតាមបែបប្រពៃណី យើងប្តេជ្ញាគាំទ្រដល់ការបង្កើនសមត្ថភាពរបស់វិស័យនេះតាមរយៈគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ និងការវាយតម្លៃហានិភ័យទីផ្សារ ដើម្បីពង្រឹងតួនាទីរបស់យើងក្នុងនាមជាដៃគូគួរជាទីទុកចិត្តនៅក្នុងវិស័យធានារ៉ាប់រងនៅកម្ពុជាដែលមានការវិវត្តន៍ឥតឈប់ឈរ។

ព្រឹត្តិការណ៍សំខាន់ៗ

2002
ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋដើម្បីគាំទ្រដល់ទីផ្សារធានារ៉ាប់រងនៅកម្ពុជា

2004
ក្លាយជាក្រុមហ៊ុនចម្រុះរដ្ឋរវាងរាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិនិយោគិនពីវិស័យឯកជន

2017
ចាប់ផ្តើមអាជីវកម្មធានារ៉ាប់រងបន្តលើអាយុជីវិត

2018
ចាប់ផ្តើមរៀបចំ និងគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រងសម្រាប់កម្មវិធី Professional Certificate in General Insurance Underwriting (PCGIU)

2019
មានការចូលរួមពីវិនិយោគិនយុទ្ធសាស្ត្រក្នុងស្រុកចំនួន២ទៀត រួមមាន ហ្វតតេអ៊ិនវេសមិនហូលឌីង ឯ.ក និង សុវណ្ណាភូមិ ឡាយហ្វ៍ អឺសួរិនស៍ ភីអិលស៊ី និងបង្កើនដើមទុនចុះបញ្ជីរហូតដល់ ១៤ លានដុល្លារអាម៉េរិក

2023
បង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធផ្នែកសេវាគាំទ្រការគ្រប់គ្រងសំណងធានារ៉ាប់រង ដោយមានឈ្មោះថា **កម្ពុជារី ប៊ូវេនឈ័រ ឯ.ក.** ដើម្បីគាំទ្រការអភិវឌ្ឍន៍ទីផ្សារធានារ៉ាប់រងនៅកម្ពុជា

ចក្ខុវិស័យ

ក្រុមហ៊ុន កម្ពុជា រី មានចក្ខុវិស័យវែងឆ្ងាយក្នុងការក្លាយខ្លួនជាដៃគូយុទ្ធសាស្ត្រក្នុងការផ្តល់ដំណោះស្រាយធានារ៉ាប់រងបន្ត ប្រកបដោយការពេញចិត្ត និងទំនុកចិត្ត ដោយដើរតួនាទីយ៉ាងសំខាន់ក្នុង ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងប្រកបដោយភាពធន់ ការបង្កើនសមត្ថភាពទទួលយកហានិភ័យ និងការពង្រីកវត្តមានរបស់ខ្លួនទៅទីផ្សារក្រៅប្រទេសដើម្បីរួមចំណែកដល់ការរក្សាស្ថិរភាពហិរញ្ញវត្ថុនៅក្នុងតំបន់។

បេសកកម្ម

ក្រុមហ៊ុន កម្ពុជា រី មានបេសកកម្មរួមចំណែកក្នុងការពង្រឹង និងលើកកម្ពស់វិជ្ជាជីវៈធានារ៉ាប់រង និងធានារ៉ាប់រងបន្តតាមរយៈការផ្តល់នូវដំណោះស្រាយធានារ៉ាប់រងបន្តសមស្រប ទុកចិត្តបាន និងប្រកបដោយនវានុវត្តន៍។ ក្រុមហ៊ុនមានគោលបំណងធ្វើជាមជ្ឈ-មណ្ឌលសម្រាប់ការប្រមូលផ្តុំ និងចែករំលែកទិន្នន័យអំពីហានិភ័យទីផ្សារ ដោយបង្កើនតម្លៃរបស់ភាគហ៊ុនិក និងអ្នកពាក់ព័ន្ធ រួមទាំង អតិថិជន ដៃគូអាជីវកម្ម និងនិយោជិត។ ដើម្បីគាំទ្រវិស័យធានារ៉ាប់រងប្រកបដោយភាពធន់ និងចីរភាពនៅកម្ពុជា ក្រុមហ៊ុន កម្ពុជា រី ប្តេជ្ញាចូលរួមសកម្មក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកធានារ៉ាប់រង និងការអភិវឌ្ឍសមត្ថភាពតាមរយៈការផ្តល់នូវកម្មវិធីបណ្តុះបណ្តាលជំនាញធានារ៉ាប់រង និងការចែករំលែកចំណេះដឹងអំពីការវិវត្តថ្មីៗនៃទីផ្សារ។ លើសពីនេះ ក្រុមហ៊ុនគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍទីផ្សារធានារ៉ាប់រង និងការគ្រប់គ្រងហានិភ័យនៅក្នុងប្រទេស រួមទាំងការកាត់បន្ថយលំហូរមូលធនទៅក្រៅប្រទេស ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសុវត្ថិភាពហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជា។

គុណតម្លៃ

សុច្ចរិតភាព

ក្រុមហ៊ុនប្រកបអាជីវកម្ម ប្រកបដោយឥរិយាបថវិជ្ជាជីវៈ និងក្រមសីលធម៌ស្របតាមស្តង់ដារខ្ពស់ ដើម្បីធានាបាននូវកេរ្តិ៍ឈ្មោះ និងការជឿទុកចិត្តកម្រិតខ្ពស់

ការផ្តោតលើអតិថិជន

ក្រុមហ៊ុនមានការប្តេជ្ញាខ្ពស់ក្នុងការផ្តល់ជូនអតិថិជននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នវានុវត្តន៍ និងស្របតាមតម្រូវការ

កត្តាមនុស្ស

ក្រុមហ៊ុនមានមោទនភាពក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងស្រុកឱ្យមានទេពកោសល្យខ្ពស់ ដោយបន្តលើកទឹកចិត្តពួកគេឱ្យស្ថិតនៅលើមាគ៌ានៃស្វ័យកែលម្អ និងភាពរីកចម្រើននៃអាជីព និងលើកកម្ពស់វប្បធម៌ភាពជាក្រុមហ៊ុនល្អ ដោយផ្សារភ្ជាប់ការលើកសរសើរ ទៅនឹងសមិទ្ធិផលរបស់បុគ្គល និងលទ្ធផលអាជីវកម្ម

កិច្ចសហការណ៍

ក្រុមហ៊ុនមានការប្តេជ្ញាខ្ពស់ ធ្វើការជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធនានា ដើម្បី កំណើន និងការអភិវឌ្ឍប្រកបដោយចិរភាពនៃវិស័យធានារ៉ាប់រង

ការគ្រប់គ្រងសាជីវកម្ម និងភាពជាអ្នកដឹកនាំ

ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន ដែលមានក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ និងអនុវត្តទិសដៅយុទ្ធសាស្ត្ររបស់ខ្លួន។ សមាជិកក្រុមប្រឹក្សាភិបាលមានបទពិសោធន៍មកពីវិស័យសាធារណៈ និងឯកជន ដែលធានាបាននូវអភិក្រមដែលមានតុល្យភាពក្នុងការសម្រេចចិត្ត។

ក្រុមប្រឹក្សាភិបាល

ឯ.ឧ រស់ សីលវ៉ា – ប្រធានក្រុមប្រឹក្សាភិបាល



ឯ.ឧ រស់ សីលវ៉ា ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន កម្ពុជា រី តាំងពីឆ្នាំ២០១២មក, មានតួនាទីសំខាន់ក្នុងការរៀបចំ អភិបាលកិច្ច និងទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។ ជាមួយនឹងអាជីពយ៉ាងទូលំទូលាយផ្នែកហិរញ្ញវត្ថុសាធារណៈ លោកបានកាន់តំណែងសំខាន់ៗនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ) តាំងពីឆ្នាំ 1994 រួមទាំងជាអភិបាលគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។ លោកក៏បានបម្រើការជាទីប្រឹក្សានាយកប្រតិបត្តិនៃក្រុមប្រឹក្សាភិបាលធនាគារពិភពលោកពីឆ្នាំ 2006 ដល់ឆ្នាំ 2008។ បច្ចុប្បន្ន លោកជារដ្ឋលេខាធិការនៅ (ក.ស.ហ.វ) និងជាសមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលរួមចំណែកយ៉ាងសកម្មដល់កំណែទម្រង់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេស។

ឯកឧត្តម ទទួលបានសញ្ញាប័ត្របរិញ្ញាបត្រ វិទ្យាសាស្ត្រសង្គម មកពីវិទ្យាស្ថាន Penza's Institute of Pedagogy អតីតសហភាពសូវៀត និង សញ្ញាប័ត្របរិញ្ញាបត្រជាន់ខ្ពស់ កិច្ចការអន្តរជាតិ ផ្នែក គ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ច មកពីសាកលវិទ្យាល័យ កូឡុំប៊ី នៅទីក្រុងញូយ៉ក សហរដ្ឋអាម៉េរិក។

លោកជំទាវ នួន សុណេតា – សមាជិកាក្រុមប្រឹក្សាភិបាល



ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន កម្ពុជា រី ក្នុងឆ្នាំ 2023 **លោកជំទាវ នួន សុណេតា** នាំមកនូវជំនាញផ្នែកច្បាប់យ៉ាងទូលំទូលាយដល់ក្រុមហ៊ុន។ លោកជំទាវគឺជាសមាជិកនៃក្រុមប្រឹក្សាច្បាប់ នៅទីស្តីការគណៈរដ្ឋមន្ត្រី និងបម្រើការជាប្រធាននាយកដ្ឋានច្បាប់ស្តីពីកិច្ចការផ្ទៃក្នុង និងបរទេស។ លើសពីនេះទៀត លោកស្រីគឺជាផ្នែកមួយនៃគណៈរដ្ឋមន្ត្រីរបស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីអចិន្ត្រៃយ៍ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

លោកជំទាវបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ (2016) និងសញ្ញាប័ត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងសាធារណៈ(2019) ពីសាកលវិទ្យាល័យកម្ពុជា។

ឯ.ឧ ប៉ែន ពេជ្រសាលី – សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម ប៉ែន ពេជ្រសាលី ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុន កម្ពុជា រី នៅឆ្នាំ2014។ ឯកឧត្តមមានបទពិសោធន៍ក្នុងវិស័យច្បាប់នៅកម្ពុជារយៈពេល ជាង២០ឆ្នាំមកហើយ។ បច្ចុប្បន្ន ឯកឧត្តមមានតួនាទីជាអគ្គនាយកនៃអគ្គនាយដ្ឋាន កិច្ចការអយ្យការនិងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ជាស្ថាប័នដែលគាត់ធ្វើការតាំងពីឆ្នាំ 1995មក។

ឯកឧត្តម ទទួលបានសញ្ញាប័ត្របរិញ្ញាប័ត្រជាន់ខ្ពស់ ផ្នែកច្បាប់ចំនួនពីរពីសាកលវិទ្យាល័យ Russian Peoples' Friendship University នៅឆ្នាំ 1995 និង ពីសាកលវិទ្យាល័យ Nagoya នៅឆ្នាំ 2002។

លោក ហ៊ុយ វ៉ាថារ៉ូ – សមាជិកក្រុមប្រឹក្សាភិបាល



លោក ហ៊ុយ វ៉ាថារ៉ូ ជាអគ្គនាយក និងសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនកម្ពុជារី ហើយក៏ជា ប្រធានសមាគមធានារ៉ាប់រងកម្ពុជា តាំងពីឆ្នាំ2014 មក។
លោកមានបទពិសោធន៍ជាង 25ឆ្នាំ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជនដែលមានបទពិសោធន៍ការងារ ទាំងវិស័យហិរញ្ញវត្ថុ និងវិស័យមិនមែនហិរញ្ញវត្ថុ។ លោកបានចាប់ផ្តើមអាជីពក្នុងវិស័យធានារ៉ាប់រង ដោយបម្រើការនៅស្ថាប័ននិយ័តករធានារ៉ាប់រង នៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មុនការចូលរួមនៅក្នុងវិស័យធានារ៉ាប់រង គាត់បានរួមចំណែកនៅក្នុងដំណើរការ បង្កើតទីផ្សារមូលបត្រជាលើកដំបូងនៅកម្ពុជា។

លោកមានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និង សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកអភិវឌ្ឍន៍អន្តរជាតិ មកពីសាកលវិទ្យាល័យអន្តរជាតិជប៉ុន នៃប្រទេសជប៉ុន។

លោក ធេឌី ហៃឡាំសាស – សមាជិកក្រុមប្រឹក្សាភិបាល



លោក ធេឌី ហៃឡាំសាស ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន កម្ពុជារី តាំងពីឆ្នាំ2004មក ដែលជាតំណាងដៃគូរភាគីយុទ្ធសាស្ត្រ។ លោកមានបទពិសោធន៍ក្នុងវិស័យធានារ៉ាប់រងរយៈពេលជាង 40ឆ្នាំ មកហើយ នៅប្រទេសឥណ្ឌូនេស៊ី។ នៅក្នុងថ្នាក់តំបន់គាត់បានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ Asian Insurance Congress និង ASEAN Insurance Council ចាប់តាំងពីឆ្នាំ 1999មក។

លោក ធេឌី ហៃឡាំសាស បានបញ្ចប់បរិញ្ញាប័ត្រពីមហាវិទ្យាល័យ South East Asia Union Colleges នៃប្រទេសសិង្ហបុរី។

លោក យក់ ចំរើនឫទ្ធិ – សមាជិកក្រុមប្រឹក្សាភិបាល



លោក យក់ ចំរើនឫទ្ធិ បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន កម្ពុជារី ចាប់តាំងពីឆ្នាំ 2019 ហើយបច្ចុប្បន្នលោកក៏ជាប្រធានអគ្គនាយកប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រងហ្វូតតេ ដែលមានភារៈទទួលខុសត្រូវលើការត្រួតពិនិត្យប្រតិបត្តិការទាំងមូលនិងកំណត់ទិសដៅយុទ្ធសាស្ត្រសម្រាប់គ្រប់ក្រុមហ៊ុនបុត្រសម្ពន្ធ័ទាំងអស់នៅក្នុងហ្វូតតេគ្រុប។ លោកក៏មានតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនផ្សេងៗផងដែរ។

លោក យក់ ចំរើនឫទ្ធិ មានបទពិសោធន៍ជំនាញជាង 30ឆ្នាំ លើផ្នែកធានារ៉ាប់រង ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុនិងយុទ្ធសាស្ត្រ។

លោកទទួលបានអនុបណ្ឌិតពីសាកលវិទ្យាល័យ Charles Sturt ។ លោកក៏ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (FMII), Associate of Chartered Insurance Institute (ACII) ,and Senor Associate of Australian and New Zealand Institute of Insurance and Finance (ANZIIF)។

លោក រ័ត្ន វាសនា – សមាជិកក្រុមប្រឹក្សាភិបាល



លោក រ័ត្ន វាសនា បានចូលរួមជាមួយ ក្រុមហ៊ុន កម្ពុជារី នៅខែមេសា ឆ្នាំ2002 ក្នុងតួនាទីជានាយកហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាភិបាល (តំណាងនិយោជិត)។ ក្នុងកំឡុងរយៈពេលជាង 20ឆ្នាំ លោកមានបទពិសោធន៍នឹងចំណេះដឹងទូលំទូលាយផ្នែកគណនេយ្យហិរញ្ញវត្ថុសម្រាប់វិស័យធានារ៉ាប់រង និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ ក្រៅពីនេះ លោកក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងតួនាទីស្នូលរបស់សមាគមធានារ៉ាប់រងកម្ពុជាក្នុងការដឹកនាំគណៈកម្មាធិការសំខាន់ៗដូចជាគណៈកម្មាធិការដោះស្រាយវិវាទលើយានយន្ត និងគណៈកម្មាធិការគណនេយ្យ។

លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកសេដ្ឋកិច្ចពី សាកលវិទ្យាល័យបច្ចេកវិទ្យានិងគ្រប់គ្រងនៅឆ្នាំ 2008 និងបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS)។

គណៈគ្រប់គ្រងសំខាន់ៗ

អគ្គនាយក

លោក **ហ៊ុយ វ៉ាថារ៉ូ** មានភាពជាអ្នកដឹកនាំបែបយុទ្ធសាស្ត្រ និងកំណត់ទិសដៅរួម ដើម្បីធានាបាននូវកំណើននិងស្ថិរភាពរបស់ក្រុមហ៊ុនរយៈពេលវែង រួមបញ្ចូលទាំងការដឹកនាំនិងការត្រួតពិនិត្យមុខងារសំខាន់ៗ រួមមាន ការវាយតម្លៃហានិភ័យធានារ៉ាប់រង ការគណនាបុព្វលាភធានារ៉ាប់រង ការគ្រប់គ្រងហានិភ័យ ហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ធុរកិច្ច។ ក្នុងពេលជាមួយគ្នា លោកមានការប្រមើមើលវែងឆ្ងាយ ក្នុងការជំរុញនិវានុវត្តន៍ដើម្បីប្រសិទ្ធភាពប្រតិបត្តិការនិងធុរកិច្ចក្នុងយុគសម័យឌីជីថល។ លោកតែងប្រកាន់ខ្ជាប់នូវអនុលោមភាពច្បាប់ ហើយបានបានចូលរួមយ៉ាងសកម្មជាមួយបុគ្គលពាក់ព័ន្ធ ដូចជានិយ័តករធានារ៉ាប់រងកម្ពុជា ដៃគូក្រុមហ៊ុនធានារ៉ាប់រង និងសមាគមធានារ៉ាប់រងកម្ពុជា ដើម្បីពង្រឹងកិច្ចសហការក្នុងការពង្រឹងវិស័យធានារ៉ាប់រងដែលនឹរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

នាយកហិរញ្ញវត្ថុ

លោក **រ័ត្ន វាសនា** ជានាយកហិរញ្ញវត្ថុ និងសមាជិកក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍ជាង 20ឆ្នាំក្នុងតួនាទីជាអ្នកដឹកនាំជាន់ខ្ពស់ដែលពោរពេញទៅដោយបទពិសោធន៍ផ្នែកគណនេយ្យហិរញ្ញវត្ថុ អភិបាលកិច្ច និងយុទ្ធសាស្ត្រហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ លោកត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយចំពោះជំនាញវិជ្ជាជីវៈអនុលោមភាព ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) និងបានចូលរួមយ៉ាងសកម្មក្នុងការជួយអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជា តាមរយៈការដឹកនាំនៅគណៈកម្មាធិការបច្ចេកទេសសំខាន់ៗ នៃសមាគមធានារ៉ាប់រងកម្ពុជា។

លោកមានសមទ្ធិផលការងារកិច្ចការពាក់ពន្ធ័និងហិរញ្ញវត្ថុស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលឆ្លុះបញ្ចាំងតាមរយៈមតិសវនករឯករាជ្យ លើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវគ្រប់ទិដ្ឋភាពជាសារវន្តជាង20ឆ្នាំ មកនេះ។ លោកក៏មានជំនាញខ្ពស់លើការគ្រប់គ្រងសវនកម្មដែលមានលក្ខណៈស្មុគស្មាញ ការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ និងយុទ្ធសាស្របង្កើនប្រាក់ចំណេញខ្ពស់ពីការវិនិយោគប្រកបដោយសុវត្ថិភាព និងធានាបាននូវការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពេញលេញនៅកម្ពុជា។

នាយកប្រតិបត្តិការ

លោក **ទី អាទិត្យ** ទទួលខុសត្រូវចំពោះការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុន ដោយផ្តោតលើការសម្រេចបាននូវកំណើនរយៈពេលវែង ប្រកបដោយនិរន្តរភាព និងប្រាក់ចំណេញ។ ក្នុងតួនាទីរបស់លោក លោកផ្តល់នូវភាពជាអ្នកដឹកនាំប្រកបដោយយុទ្ធសាស្ត្រក្នុងកិច្ចប្រតិបត្តិការវាយតម្លៃហានិភ័យ ត្រួតពិនិត្យលើការរៀបចំនិងការអនុវត្តលើក្របខ័ណ្ឌវាយតម្លៃហានិភ័យ។ លោក **ទិត្យ** ធ្វើការយ៉ាងជិតស្និទ្ធជាមួយមុខងារផ្សេងៗដើម្បីវិភាគនិន្នាការទីផ្សារ វាយតម្លៃហានិភ័យដែលទទួលយក និងរៀបចំដំណោះស្រាយធានារ៉ាប់រងបន្ត អោយស្របតាមតម្រូវការរបស់អតិថិជននិងគោលបំណងរបស់ក្រុមហ៊ុន។ កិច្ចខិតខំប្រឹងប្រែងរបស់លោកមានសារៈសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពធានារ៉ាប់រងបន្ត ដើម្បីធានាថាកិច្ចប្រតិបត្តិការលើការវាយតម្លៃនិងទទួលយកហានិភ័យទទួលបាននូវភាពប្រកួតប្រជែង ភាពធន់ទៅនឹងការប្រែប្រួលទីផ្សារ និងស្របតាមចក្ខុវិស័យធុរកិច្ចយ៉ាងទូលំទូលាយរបស់ក្រុមហ៊ុន។ ក្នុងយុទ្ធសាស្ត្រ សម្លឹងឆ្ពោះទៅមុខនិងប្រកបដោយបរេសកម្ម លោករួមចំណែកក្នុងការរក្សាជំហរក្រុមហ៊ុនក្នុងទីផ្សារធានារ៉ាប់រងបន្តដែលកំពុងវិវត្តន៍ និងមានភាពស្មុគស្មាញ។

ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម

ក្នុងនាមជាប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម លោកស្រី **ជូ សុរម្យនាថ** បានដឹកនាំអភិវឌ្ឍន៍និងអនុវត្តយុទ្ធសាស្ត្រដែលផ្តោតលើអតិថិជនដោយកំណត់ឱកាសទីផ្សារថ្មី ពង្រឹងនិងពង្រីកទំនាក់ទំនងល្អជាមួយអតិថិជនសក្តានុពល និងបង្កើនវត្តមានរបស់ក្រុមហ៊ុនក្នុងទីផ្សារ។ លោកស្រី បានសហការយ៉ាងជិតស្និទ្ធជាមួយក្រុមកាងារវាយតម្លៃហានិភ័យធានារ៉ាប់រង អ្នកគណនាបុព្វលាភធានារ៉ាប់រង និងការកំណត់នូវហានិភ័យច្បាស់លាស់ ដើម្បីឆ្លើយតបតាមតម្រូវការធានារ៉ាប់រងបន្តរបស់អតិថិជន និងផ្តល់នូវដំណោះស្រាយធានារ៉ាប់រងបន្តសមស្របប្រកបដោយវិជ្ជាជីវៈ។ ដើម្បីផ្តល់នូវដំណោះស្រាយទាំងនេះស្របតាមគោលដៅអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន លោកស្រី **សុរម្យនាថ** ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនអាជីវកម្មប្រកបដោយនិរន្តរភាព និងធានាថាក្រុមហ៊ុនមានភាពប្រកួតប្រជែងនៅក្នុងទីផ្សារ។

ប្រធានផ្នែកហិរញ្ញវត្ថុ

កញ្ញា **ងួន ណាំសិរីវិជ្ជនី** ទទួលខុសត្រូវក្នុងការត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ធានារបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងផ្តល់ការគាំទ្រការសម្រេចចិត្តជាយុទ្ធសាស្ត្ររបស់ថ្នាក់ដឹកនាំ។ តួនាទីរបស់កញ្ញា រួមមានការរៀបចំផែនការថវិកា ការវិភាគលើការវិនិយោគ និងការរៀបចំផែនការហិរញ្ញវត្ថុ ដើម្បីធានាបានប្រាក់ចំណេញខ្ពស់ និងនិរន្តរភាពរយៈពេលវែង។ កញ្ញាធានានូវការអនុលោមតាមបទប្បញ្ញត្តិដែលពាក់ពន្ធ័ធានារ៉ាប់រង អនុលោមភាពស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។ តាមរយៈការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំ កញ្ញា **វិជ្ជនី** ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គោលដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងពង្រឹងភាពធន់ប្រតិបត្តិការអាជីវកម្ម។

ប្រធានផ្នែកវិភាគហានិភ័យធានារ៉ាប់រងអាយុជីវិត និងសុខភាព

លោកស្រី **ពេជ្រ សុគន្ធារី** ប្រធាន វិភាគហានិភ័យធានារ៉ាប់រងអាយុជីវិត និងសុខភាព,មានតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃហានិភ័យ និងការសម្រេចចិត្តទទួលយកហានិភ័យលើធានារ៉ាប់រងអាយុជីវិត និងសុខភាព។ លោកស្រីទទួលខុសត្រូវក្នុងការវាយតម្លៃហានិភ័យនៃការធានារ៉ាប់រង និងធ្វើការសម្រេចចិត្តប្រកបដោយវិជ្ជាជីវៈដែលថ្លឹងថ្លែងលើផ្តល់ការធានារ៉ាប់រងជាមួយនឹងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។ ការងារសំខាន់ៗរបស់លោកស្រី ធានាថាហានិភ័យត្រូវបានកំណត់ច្បាស់លាស់ តម្លៃ និងអាចគ្រប់គ្រងបាន ស្របតាមកម្រិតការទទួលយកហានិភ័យរបស់ក្រុមហ៊ុន ដើម្បីធានាបាននូវប្រាក់ចំណេញ និងនិរន្តរភាពអាជីវកម្មធានារ៉ាប់រងបន្ត។

ប្រធានផ្នែកព័ត៌មានវិទ្យា

លោក **ឡៃ លីម** ប្រធានផ្នែកព័ត៌មានវិទ្យា ជាមួយបទពិសោធន៍ជាង 9ឆ្នាំ ក្នុងវិស័យព័ត៌មានវិទ្យានៅក្នុងវិស័យធានារ៉ាប់រង។ លោកមានជំនាញពិសេសក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ការពារសន្តិសុខសាយប័រ និងការអភិវឌ្ឍកម្មវិធីប្រព័ន្ធគ្រប់គ្រងអាជីវកម្មធានារ៉ាប់រងបន្ត។ លោកបានបង្ហាញពីសមត្ថភាពក្នុងការសហការរវាង អង្គភាពព័ត៌មានវិទ្យា និងនាយកដ្ឋានផ្សេងៗ ដើម្បីផ្តល់ដំណោះស្រាយបច្ចេកវិទ្យាដែលសមស្របនឹងតម្រូវការអាជីវកម្ម។ លើសពីនេះទៀត លោក **លីម** ក៏មានជំនាញខ្ពស់ក្នុងការគ្រប់គ្រងថវិកា ការបែងចែកធនធាន និងការបង្កើតទំនាក់ទំនងល្អជាមួយអ្នកផ្គត់ផ្គង់ ដែលជួយពង្រឹងប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន និងជំរុញការផ្លាស់ប្តូរទៅជាឌីជីថល។


ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

ក្នុងនាមជាប្រធានសវនកម្មផ្ទៃក្នុង លោកស្រី **រឿន ពេជ្ររ៉ា** មានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសុចរិតភាព ភាពធន់ និងការត្រួតពិនិត្យបែបយុទ្ធសាស្ត្រនៅក្នុងក្រុមហ៊ុន។ លោកស្រីធ្វើការវាយតម្លៃឯករាជ្យនៃការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងការអនុវត្តអភិបាលកិច្ច ដើម្បីធានាបាននូវអនុលោមភាព និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ។ តាមរយៈសវនកម្មលម្អិត និងការដោះស្រាយបញ្ហាផ្សេងៗ លោកស្រីបានជំរុញការកែលម្អជាបន្តបន្ទាប់តាមរយៈអនុសាសន៍អាចអនុវត្តបាន ដែលទទួលបានមកពីការងារសវនកម្ម និងពង្រឹងគណនេយ្យភាពនៅក្នុងក្រុមហ៊ុន។ អភិក្រមសកម្មរបស់លោកស្រី ជួយកំណត់ហានិភ័យដែលអាចកើតមានឡើង ខណៈពេលដែលការប្តេជ្ញារបស់លោកស្រីចំពោះតម្លាភាពបានបង្កើតទំនុកចិត្តពីភាគីពាក់ព័ន្ធ។

លទ្ធផលហិរញ្ញវត្ថុ

បុព្វលាភធានារ៉ាប់រងដុល


ក្រុមហ៊ុន កម្ពុជា រី បន្តសម្រេចបានកំណើនហិរញ្ញវត្ថុរឹងមាំ ដោយបុព្វលាភដុលសរុបបានកើនឡើងជិត 40% គឺកើនឡើងពី 14.3 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2020 ដល់ 19.9 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2024។ បុព្វលាភបានកើនឡើងជិត 5% ក្នុងឆ្នាំ2024 ធៀបនឹងឆ្នាំ2023។ កំណើនដ៏គួរឱ្យកត់សម្គាល់នេះឆ្លុះបញ្ចាំងពីតួនាទីរបស់ក្រុមហ៊ុន កម្ពុជា រី ដែលចេះតែរីកធំឡើងក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់ជាតិ តាមរយៈការចាប់យកកាលានុវត្តភាពទីផ្សាររបស់ខ្លួន និង ការផ្តល់នូវដំណោះស្រាយហានិភ័យដែលអាចទុកចិត្តបាន។



បុព្វលាភធានារ៉ាប់រងដុល របស់ កម្ពុជា រី ឆ្នាំ 2024 **$19.91M** **5%**


ផ្នែកធានារ៉ាប់រងទូទៅនៅតែជាកម្លាំងចលករក្នុងការជំរុញឱ្យមានកំណើននេះ ដោយមានចំណែក 96.5% នៃប្រាក់ចំណូលបុព្វលាភដុលសរុបរបស់ ក្រុមហ៊ុន កម្ពុជា រី ហើយចំណែកផ្សេងទៀតនៃបុព្វលាភដុលរបស់ក្រុមហ៊ុនបានមកពីផ្នែកធានារ៉ាប់រងអាយុជីវិត។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ បុព្វលាភទទួលបានពីផ្នែកធានារ៉ាប់រងទូទៅ កើនឡើងប្រមាណ 40% គឺកើនពី 13.7 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2020 ដល់ 19.2 លានដុល្លារអាម៉េរិកក្នុងឆ្នាំ 2024 ដែលភាគច្រើនបានមកពីផលិតផលធានារ៉ាប់រងទ្រព្យសម្បត្តិ (អគ្គីភ័យ) យានយន្ត និងសុខភាព។

ខណៈពេលដែលផ្នែកធានារ៉ាប់រងអាយុជីវិតមានកំណើនកម្រិតមធ្យម ប្រភពចំណូលនេះរក្សាបាននូវការកើនឡើងតិចតួចត្រឹម 5%ក្នុងរយៈពេលដូចគ្នាគឺកើនពី 612,042 ដុល្លារអាម៉េរិកក្នុងឆ្នាំ 2020 ដល់ 649,093 ដុល្លារអាម៉េរិកក្នុងឆ្នាំ 2024។



សំណងទូទាត់ដុល


ក្រុមហ៊ុន កម្ពុជា រី បានប្រកាន់ខ្ជាប់នូវតួនាទីរបស់ខ្លួនក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តឈានមុខគេរបស់ប្រទេស ដោយគាំទ្រវិស័យធានារ៉ាប់រងទាំងការរុញច្រានកំណើន និងការដោះស្រាយបញ្ហាប្រឈម។ ក្នុងឆ្នាំ 2024 ក្រុមហ៊ុន កម្ពុជា រី ប្រឈមនឹងសំណងធានារ៉ាប់រងខ្ពស់មិនធ្លាប់មានដែលគិតជាទឹកប្រាក់មានចំនួន 11 លានដុល្លារអាម៉េរិក ច្រើនជាងទ្វេដងធៀបនឹងសំណងក្នុងឆ្នាំ2020 ដែលមានត្រឹម 4.8 លានដុល្លារអាម៉េរិក។ គ្រាន់តែក្នុងឆ្នាំ2024 នេះសំណងធានារ៉ាប់រងបានកើនឡើងដល់ទៅ 47% ធៀបនឹងឆ្នាំ2023 ដែលមានចំនួន 7.5 លានដុល្លារអាម៉េរិក។ សំណងដែលកើតឡើងក្នុងផ្នែកធានារ៉ាប់រងទូទៅមានចំណែកដល់ទៅ 94% គិតជាទឹកប្រាក់សរុប 10.3 លានដុល្លារអាម៉េរិក ក្នុងឆ្នាំ2024។ អគ្គីភ័យធំៗពីរបានកើតឡើងក្នុងឆ្នាំ2024 ដែលមានទឹកប្រាក់សំណងសរុបជាង 12.9លានដុល្លារអាម៉េរិក ក្នុងនោះក្រុមហ៊ុន កម្ពុជា រី បានទទួលបន្ទុកផ្តល់សំណងជាទឹកប្រាក់ចំនួនជាង 2.5លានដុល្លារអាម៉េរិក។ សំណងទាំងអស់នេះត្រូវបានទូទាត់សងរួចរាល់នៅក្នុងឆ្នាំតែម្តង។




សំណងទូទាត់ដុល របស់ កម្ពុជា រី ឆ្នាំ 2024 **$11 លាន** **47% ▲**

សម្រាប់ផ្នែកធានារ៉ាប់រងអាយុជីវិត ទោះបីជាបុព្វលាភពីផ្នែកនេះមានចំណែកតិចតួច ប៉ុន្តែសំណងផ្នែកធានារ៉ាប់រងអាយុជីវិតមានកម្រិតខ្ពស់ដែលមិនសមាមាត្រនឹងបុព្វលាភ ពោលគឺការទូទាត់សំណងដុលមានចំនួនសរុប $654,305 លើសពីទំហំបុព្វលាភទទួលបានដែលមានចំនួនតែ $649,093។ នេះបញ្ជាក់ពីការប្តេជ្ញាចិត្តរយៈពេលវែងរបស់ក្រុមហ៊ុន កម្ពុជា រី ក្នុងការគាំទ្រការអភិវឌ្ឍវិស័យធានារ៉ាប់រង ដោយធានាថាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលជាដៃគូរបស់ក្រុមហ៊ុនកម្ពុជា រី នៅតែអាចបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង ដែលជាការលើកកម្ពស់ទំនុកចិត្ត និងស្ថិរភាពទីផ្សារ។

ចំណេញពីធានារ៉ាប់រងដុល និង ប្រាក់ចំណេញសុទ្ធ





ចំណេញពីធានារ៉ាប់រងដុល
របស់ កម្ពុជា រី ឆ្នាំ **2024** **$2.7 លាន**

ប្រាក់ចំណេញសុទ្ធ
របស់ កម្ពុជា រី ឆ្នាំ **2024** **$1.4 លាន**

នៅឆ្នាំ 2024 ប្រាក់ចំណេញធានារ៉ាប់រងដុលរបស់ ក្រុមហ៊ុន កម្ពុជា រី មានចំនួន 2.7 លានដុល្លារអាម៉េរិក ធ្លាក់ចុះ 24% ធៀបនឹងឆ្នាំ2023ដែលមានចំនួន 3.5 លានដុល្លារអាម៉េរិក។ ការធ្លាក់ចុះនេះបណ្តាលមកពីការចំណាយខ្ពស់លើការទូទាត់សំណងដោយសារតែការកើនឡើងនៃសំណងដែលកើតឡើងកាន់តែញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ។ នេះគួសបញ្ជាក់ពីការកើនឡើងភាពនៃភាពស្មុគស្មាញនៃហានិភ័យនៅក្នុងទីផ្សារធានារ៉ាប់រងដែលចេះតែមានការវិវត្តនាពេលបច្ចុប្បន្ន។


ជាលទ្ធផល ប្រាក់ចំណេញសុទ្ធក្នុងឆ្នាំនេះ សម្រេចបាន 1.4 លានដុល្លារអាម៉េរិក ធ្លាក់ចុះប្រមាណ 40% ធៀបនឹងឆ្នាំ2023 ដែលមានចំនួន 2.48 លានដុល្លារអាម៉េរិក។

ការគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុន កម្ពុជា រី ប្រើប្រាស់ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យដ៏រឹងមាំដើម្បីកាត់បន្ថយហានិភ័យធានារ៉ាប់រង និងហិរញ្ញវត្ថុ។ ក្រុមហ៊ុនកំណត់នូវកម្រិតទំហំហានិភ័យធានារ៉ាប់រងដែលត្រូវទទួល កម្រិតរក្សាទុកហានិភ័យជាយុទ្ធសាស្ត្រ យុទ្ធសាស្ត្រធានារ៉ាប់រងបន្ត និងការធ្វើពិពិធកម្មហានិភ័យដើម្បីគ្រប់គ្រងហានិភ័យធានារ៉ាប់រង។ ដើម្បីគ្រប់គ្រងទ្រព្យសកម្មវិនិយោគឱ្យបានល្អ ក្រុមហ៊ុនផ្តោតលើការគ្រប់គ្រងហានិភ័យឥណទាន ការកាត់បន្ថយហានិភ័យសន្ទនីយភាព និងការធ្វើពិពិធកម្មហានិភ័យ។ អភិក្រមដ៏ទូលំទូលាយនេះត្រូវបានដាក់ចេញដើម្បីធានាថាក្រុមហ៊ុនអាចរក្សាបាននូវស្ថានភាពហិរញ្ញវត្ថុដែលមានស្ថិរភាពអំឡុងពេលទីផ្សារមានភាពមិនប្រាកដប្រជា។

សមិទ្ធផលសំខាន់ៗ

ប្រទេសនានាក្នុងតំបន់ប្រឈមនឹងបម្រែបម្រួលអាកាសធាតុកាន់តែខ្លាំងឡើង និងគ្រោះមហន្តរាយធម្មជាតិដែលកើនឡើងកាន់តែញឹកញាប់។ ស្ថានការនេះបង្កនូវ ហានិភ័យកាន់តែធំដល់ស្ថិរភាពសេដ្ឋកិច្ច និងបង្ហាញ ពីតម្រូវការចាំបាច់ដើម្បីពង្រីកអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច។ ក្រុមហ៊ុន កម្ពុជា រីបានផ្តល់ការគាំទ្រធានារ៉ាប់រងបន្តដល់គម្រោងសាកល្បងដែលផ្តល់ការធានារ៉ាប់រងលើដំណាំដោយផ្អែកលើសន្ទស្សន៍អាកាសធាតុក្នុងគោលបំណងដើម្បីគាំទ្រដល់កំណើនវិស័យកសិកម្មក្នុងរយៈពេល3ឆ្នាំចុងក្រោយនេះ។



ការបង្កើតក្រុមហ៊ុនកម្ពុជារី ប្លូវេនឈ័រ ឯ.ក ក្នុងឆ្នាំ 2023 គឺជាការពង្រីកខ្លួនមួយជំហានដើម្បីចាប់យកកាលានុវត្តភាពធុរកិច្ចផ្នែកសេវាកម្មគ្រប់គ្រងសំណងធានារ៉ាប់រង។ ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅឆ្នាំ 2024 ក្នុងគោលបំណងបង្កើនសេវាកម្មរបស់ខ្លួន និងផ្តល់ដំណោះស្រាយដ៏ទូលំទូលាយដល់អតិថិជន។ ការផ្លាស់ប្តូរបែបយុទ្ធសាស្ត្រនេះមិនត្រឹមតែពង្រីកសមត្ថភាពរបស់ក្រុមហ៊ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងជំហរប្រកួតប្រជែងរបស់ខ្លួននៅក្នុងទីផ្សារផងដែរ។

បម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ៖ ប្រទេសនានាក្នុងតំបន់ប្រឈមនឹងបម្រែបម្រួលអាកាសធាតុ កាន់តែខ្លាំងឡើង និងគ្រោះមហន្តរាយធម្មជាតិដែលកើនឡើងកាន់តែញឹកញាប់។ ស្ថានការនេះបង្កនូវហានិភ័យកាន់តែធំដល់ស្ថិរភាពសេដ្ឋកិច្ច និងបង្ហាញពីតម្រូវការចាំបាច់ដើម្បីពង្រីកអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច។ ក្រុមហ៊ុន កម្ពុជា រីបានផ្តល់ការគាំទ្រធានារ៉ាប់រងបន្តដល់គម្រោងសាកល្បងដែលផ្តល់ការធានារ៉ាប់រងលើដំណាំដោយផ្អែកលើសន្ទស្សន៍អាកាសធាតុក្នុងគោលបំណងដើម្បីគាំទ្រដល់កំណើនវិស័យកសិកម្មក្នុងរយៈពេល3ឆ្នាំចុងក្រោយនេះ។

ភាពជាដៃគូ

ក្រុមហ៊ុន កម្ពុជា រី បានពង្រីកដៃគូរបស់ខ្លួនស្របពេលនឹងការរីកចម្រើននៃវិស័យធានារ៉ាប់រងកម្ពុជា។ ក្រុមហ៊ុន កម្ពុជា រី បានពង្រីកដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងទូទៅពី 13ក្រុមហ៊ុន ក្នុងឆ្នាំ 2019 ដល់ 18ក្រុមហ៊ុន នៅឆ្នាំ 2024 ដែលឆ្លុះបញ្ចាំងពីកំណើននៃវិស័យនេះ។


ក្នុងផ្នែកធានារ៉ាប់រងអាយុជីវិតវិញ ក្រុមហ៊ុន កម្ពុជា រី បានបង្កើតភាពជាដៃគូដំបូងរបស់ខ្លួនជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្នុងឆ្នាំ 2017 និងបានពង្រីកដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតផ្សេងទៀតជាបន្តបន្ទាប់រហូតដល់ចំនួន 9 នៅឆ្នាំ 2024។ វិស័យធានារ៉ាប់រងអាយុជីវិតមានកំណើនគួរឱ្យកត់សម្គាល់ចាប់តាំងពីការចាប់ផ្តើមនៅឆ្នាំ 2012។ នៅឆ្នាំ 2018 ចំនួនក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតបានកើនឡើងដល់ចំនួន8 ដោយបុព្វលាភទីផ្សារធានារ៉ាប់រងអាយុជីវិតសរុបឈានដល់ 99 លានដុល្លារអាម៉េរិក លើសពីបុព្វលាភទីផ្សារធានារ៉ាប់រងទូទៅជាលើកដំបូង។ គិតត្រឹមឆ្នាំ 2024 ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមានចំនួន 14 ដែលដំណើរការនៅក្នុងប្រទេសកម្ពុជា បង្ហាញពីការពង្រីកយ៉ាងឆាប់រហ័សរបស់វិស័យនេះ។

ការគ្រប់គ្រងការវិនិយោគ

ទ្រព្យសកម្មរបស់ក្រុមហ៊ុន កម្ពុជា រី ភាគច្រើន ស្ថិតក្នុងទម្រង់ជាទ្រព្យសកម្មវិនិយោគ និងសាច់ប្រាក់នៅក្នុងគណនីចរន្តដែលត្រូវបានរក្សាក្នុងកម្រិតសមស្របមួយ សម្រាប់បំពេញតម្រូវការលំហូរសាច់ប្រាក់នៅក្នុងធុរកិច្ចរបស់ខ្លួន។

ផ្អែកលើស្ថានភាពជាក់ស្តែងនៃទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា មូលនិធិវិនិយោគរបស់ក្រុមហ៊ុន កម្ពុជា រី ភាគច្រើនលើសលប់ត្រូវបានវិនិយោគក្នុងទម្រង់ជាប្រាក់បញ្ញើមានកាលកំណត់នៅធនាគារ ដែលផ្តល់នូវប្រភពបន្ថែមនៃប្រាក់ចំណូលចរន្តរបស់ក្រុមហ៊ុន។

ក្នុងពេលដែលមូលបត្ររដ្ឋទើបចាប់ផ្តើមបោះផ្សាយ ក្រុមហ៊ុន កម្ពុជារី បានធ្វើពិពិធកម្មទ្រព្យវិនិយោគ ដោយវិនិយោគមូលនិធិរបស់ខ្លួនមួយផ្នែកទៅលើទ្រព្យសកម្មដែលមានហានិភ័យទាប គឺសញ្ញាប័ណ្ណរដ្ឋ ដើម្បីគាំទ្រដល់គម្រោងអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាលកម្ពុជា។



ទ្រព្យសកម្មវិនិយោគរបស់ក្រុមហ៊ុន កម្ពុជា រី ឆ្នាំ 2024

គណនីប្រាក់បញ្ញើមានកាលកំណត់	**$26.7 លាន**	មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន)	**$0.3 លាន**
មូលបត្រកំណល (មូលបត្ររដ្ឋ)	**$2 លាន**	ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ	**$0.3 លាន**
សមតុល្យសាច់ប្រាក់	**$0.8 លាន**	មូលបត្រកំណល (សាជីវកម្ម)	**$0.2 លាន**

សរុប $30.2 លាន 1.8%

ការលើកកម្ពស់ជំនាញធានារ៉ាប់រង តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ

ក្រុមហ៊ុន កម្ពុជា រី បន្តប្តេជ្ញាយ៉ាងមុតមាំក្នុងការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រងតាមរយៈការអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន។


ក្រុមហ៊ុន កម្ពុជា រី បានឧបត្ថម្ភកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់ដោយស្ថាប័នអប់រំវិជ្ជាជីវៈធានារ៉ាប់រងដែលមានការទទួលស្គាល់ក្នុងតំបន់ និងសាកល ទាំងផ្នែកធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងទូទៅ។ ក្នុងរយៈពេល 8 ឆ្នាំកន្លងមកនេះ ក្រុមហ៊ុន កម្ពុជា រី បានឧបត្ថម្ភកម្មវិធីបណ្តុះបណ្តាលទាំងនេះដែលមានបុគ្គលិកវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រងចំនួន 277 នាក់បានចូលរួម។

បន្ថែមលើកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុន កម្ពុជា រី ក៏បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានាដើម្បីលើកកម្ពស់ជំនាញបច្ចេកទេស និងចំណេះដឹងធានារ៉ាប់រងដោយមានការចូលរួមពីវាគ្មិនជំនាញមកពីទីផ្សារក្រៅប្រទេស។ ក្នុងឆ្នាំ2024នេះ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាព និងលើកកម្ពស់ការចែករំលែកចំណេះដឹងសម្រាប់បុគ្គលិកវិជ្ជាជីវៈក្នុងទីផ្សារធានារ៉ាប់រង។

1. ឆ្នាំ2024 - AAii (former AMii) មានអ្នកចូលរួមចំនួន **20នាក់**



2. ឆ្នាំ2024 -Aii (former MII-PCGIU) មានអ្នកចូលរួមចំនួន **24** នាក់



3. FLMI (Fellow, Life Management Institute)- Level 1 and Associate, Life Management Institute (ALMI) ឆ្នាំ2024, **Self learning** - មានអ្នកចូលរួមចំនួន **23** នាក់

វគ្គបណ្តុះបណ្តាលឯកទេសស្តីពីការវាយតម្លៃហានិភ័យអគ្គីភ័យ ដែលរៀបចំឡើងដោយ Firemax Engineering G Co Ltd ទទួលបានការចូលរួមពីអ្នកជំនាញក្នុងវិស័យចំនួន 20 នាក់។ វគ្គសិក្សានេះបានផ្តល់ការយល់ដឹងជាក់ស្តែងអំពីការវាយតម្លៃគ្រោះថ្នាក់អគ្គីភ័យ យុទ្ធសាស្ត្រការពារ និងបច្ចេកទេសកាត់បន្ថយហានិភ័យ។



វគ្គសិក្សាវាយតម្លៃហានិភ័យអគ្គីភ័យ 2024 - អ្នកចូលរួមចំនួន 20នាក់

រៀបចំឡើងដោយ MII និង Aon វគ្គនេះត្រូវបានរៀបចំឡើងសម្រាប់អ្នកចូលរួមចំនួន 25 នាក់មកពីនិយ័តករធានារ៉ាប់រងកម្ពុជា (IRC) ដែលគ្របដណ្តប់លើគោលការណ៍ធានារ៉ាប់រងបន្តសំខាន់ៗ ការអនុវត្តទីផ្សារ និងការពិចារណាលើបទប្បញ្ញត្តិ។



វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការធានារ៉ាប់រងបន្តសម្រាប់និយ័តករធានារ៉ាប់រងកម្ពុជា 2024 អ្នកចូលរួមចំនួន 25នាក់

ការចូលរួមវិស័យ និងព្រឹត្តិការណ៍ឯកទេស

ព្រឹត្តិការណ៍បណ្តាញ និងការចែករំលែកចំណេះដឹងឈានមុខគេ ដែលមានការចូលរួមដោយអ្នកជំនាញក្នុងវិស័យចំនួន 37 នាក់ ធ្វើរៀបចំឡើងដោយសហការជាមួយ Aon ។



វេទិកាជួបជុំថ្នាក់ដឹកនាំធានារ៉ាប់រង និងធានារ៉ាប់រងបន្តនៅកម្ពុជា 2024
អ្នកចូលរួមចំនួន 37នាក់

វគ្គឯកទេសដែលដឹកនាំដោយ Guy Carpenter សម្រាប់អ្នកចូលរួមចំនួន 60 នាក់ ដោយផ្តោតលើការវាយតម្លៃហានិភ័យគ្រោះមហន្តរាយ បច្ចេកទេសគំរូ និងយុទ្ធសាស្ត្រត្រៀមរៀបចំគ្រោះមហន្តរាយ។



សិក្ខាសាលាស្តីពីគំរូគ្រោះមហន្តរាយសម្រាប់ការធានារ៉ាប់រងមិនមែនអាយុជីវិត 2024
អ្នកចូលរួមចំនួន 60នាក់

ក្រុមហ៊ុន កម្ពុជា រី បានគាំទ្រការជួបជុំប្រចាំឆ្នាំនៃអ្នកជំនាញផ្នែក actuarial ចំនួន 50 នាក់នេះ ដោយជំរុញការសន្ទនាស្តីពីការវិភាគការស្លាប់ និងការអភិវឌ្ឍផលិតផលធានារ៉ាប់រង



ការឧបត្ថម្ភដល់កម្មវិធីចែករំលែករបាយការណ៍អត្រាមរណភាពប្រចាំឆ្នាំរបស់ក្រុមការងារ Actuarial Cambodia 2024
អ្នកចូលរួមចំនួន 50នាក់

សកម្មភាពទទួលខុសត្រូវខាងសង្គម

ក្រុមហ៊ុន កម្ពុជា រី ប្តេជ្ញាផ្តល់ការគាំទ្រសប្បុរសធម៌ជូនដល់សហគមន៍ដែលមានតម្រូវការតាមរយៈការអនុវត្តសកម្មភាពទទួលខុសត្រូវខាងសង្គម។

មូលនិធិគន្ធបុប្ផា

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តនេះ ក្រុមហ៊ុន កម្ពុជា រី បានរួមចំណែកជាថវិកាដល់ “មូលនិធិគន្ធបុប្ផា” ដើម្បីគាំទ្រនិរន្តរភាពរយៈពេលវែងរបស់មន្ទីរពេទ្យគន្ធបុប្ផា។ សកម្មភាពនេះឆ្លុះបញ្ចាំងពីការរួមចំណែករបស់ក្រុមហ៊ុនក្នុងការលើកកម្ពស់សេវាថែទាំសុខភាពសម្រាប់កុមារនៅកម្ពុជា។



គាំទ្រដល់ការអប់រំនៅសាលាបឋមសិក្សាជ្រៃអណ្តែត

ជាផ្នែកមួយនៃការប្តេជ្ញារបស់ខ្លួនក្នុងការអភិវឌ្ឍសហគមន៍ ក្រុមហ៊ុន កម្ពុជា រី បានផ្តល់សម្ភារៈសិក្សា និងថវិកាសម្រាប់ការជួសជុលសាលាបឋមសិក្សាជ្រៃអណ្តែត ស្ថិតនៅភូមិព្រែកតាព្រហ្ម ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល។ តាមរយៈការវិនិយោគលើធនធាន និងហេដ្ឋារចនាសម្ព័ន្ធបម្រើដល់ការអប់រំ ក្រុមហ៊ុនមានគោលបំណងបង្កើតឱ្យមានបរិយាកាសកាន់តែប្រសើរសម្រាប់ការសិក្សារបស់សិស្សានុសិស្ស និងផ្តល់ភាពជឿជាក់ទៅដល់អ្នកជំនាន់ក្រោយ ។



ព្រឹត្តិការណ៍សប្បុរសធម៌កីឡាវាយសីធានារ៉ាប់រងដែលរៀបចំដោយសមាគមធានារ៉ាប់រងកម្ពុជា

ក្រុមហ៊ុន កម្ពុជា រី មានមោទនភាពដែលបានក្លាយជាអ្នកឧបត្ថម្ភ “កម្រិតប្រាក់” ក្នុងព្រឹត្តិការណ៍សប្បុរសធម៌កីឡាវាយសីធានារ៉ាប់រងដែលរៀបចំឡើងដោយសមាគមធានារ៉ាប់រងកម្ពុជា នៅថ្ងៃទី 21-22 ខែមិថុនា ឆ្នាំ 2024។ គំនិតផ្តួចផ្តើមនេះបានប្រមែប្រមូលថវិកាសប្បុរសធម៌ដើម្បីគាំទ្រដល់ដំណើរការមន្ទីរពេទ្យគន្ធបុប្ផា និងមន្ទីរពេទ្យកុមារអង្គរ ដែលនេះក៏ជាការប្តេជ្ញារបស់ក្រុមហ៊ុនកម្ពុជា រី ក្នុងការលើកកម្ពស់សេវាថែទាំសុខភាពកុមារកម្ពុជា។



សម្រាប់ព័ត៌មានបន្ថែម



លេខទូរស័ព្ទទំនាក់ទំនង

(+855 23 880 222)

អ៊ីម៉ែល

cambodiare@cambodiare.com.kh

គេហទំព័រ

www.cambodiare.com.kh

អាសយដ្ឋាន

ផ្ទះលេខ 17, ផ្លូវ 134, សង្កាត់
មិត្តភាព, ខណ្ឌ 7 មករា, ភ្នំពេញ,
កម្ពុជា